# ជំពូកទី ៩: សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៩.១ សេចក្តីសន្និដ្ឋាន

គំរោង**មរកត**ទទួលបានសិទ្ធិវិនិយោគពេញលេញរបស់ក្រុមហ៊ុនឯកជនឈ្មោះ (ក្រុមហ៊ុនកោះពស់ ខេមបូឌា អ៊ិនវេសមេនគ្រុប អិលធីឌី)។ សមាសភាពនៃគំរោងមាន៣ផ្នែកសំខាន់គឺ ការអភិវឌ្ឍលើកោះពស់ ការអភិវឌ្ឍលើឆ្នេរកោះសេះ(ឆ្នេរហាវ៉ៃ) និងការសាងសង់ស្ពានកោះពស់ ដែលស្ថិតនៅក្នុងភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុនៃព្រះរាជាណាចក្រកម្ពុជា។ ប្រភេទនៃគំរោងគឺ សាងសង់ ប្រតិបត្តការ និងផ្ទេរ (BOT) ដោយមានទុនវិនិយោគសរុបចំនួន ៤៤០ លានដុល្លាអាមេរិក។

ការសាងសង់គំរោង**មរកត** នឹងបណ្តាលឱ្យមានហេតុប៉ះពាល់មធ្យមទៅលើធនធានធម្មជាតិ ដូចជា ព្រៃឈើ និងធនធានអេកូឡូស៊ីនៅក្នុងតំបន់កោះពស់ ជលផល និងគុណភាពទឹកអំឡុងពេលសាងសង់។ គំរោងនេះអាចបណ្តាលឱ្យមានហេតុប៉ះពាល់តិចតួចផងដែរទៅលើធនធានសង្គម រួមមាន បញ្ហាចរាចរណ៍ សកម្មភាពនេសាទត្រីរបស់អ្នកនេសាទមួយចំនួននៅជិតទីតាំងគំរោង សុខភាពសាធារណៈ ផ្លូវនាវាចរណ៍ (ក្នុងពេលសាងសង់ស្ពាន) កាកសំណល់ សំលេង និងរំញ័រ។ ទោះជាយ៉ាងណាក៏ដោយ វិធានការបន្ធូរបន្ថយត្រូវបានរៀបចំនៅក្នុងផែនការគ្រប់គ្រងបរិស្ថានសំរាប់គំរោង ដែលអាចជួយកាត់បន្ថយនូវហេតុប៉ះពាល់ទាំងនោះបានយ៉ាងច្រើន។

យ៉ាងណាមិញ គំរោងនេះនឹងផ្តល់ឱ្យនូវផលប្រយោជន៍ច្រើនទៅដល់ប្រជាជនមូលដ្ឋាន ដូចជា ផ្តល់ឱកាសការងារ ទាំងនៅក្នុងរយៈពេលសាងសង់ និងប្រតិបត្តិគំរោង។ គំរោងនឹងបានបន្ថែមហេដ្ឋារចនាសម្ព័ន្ធចំរុះនៅក្នុងក្រុងព្រះសីហនុ ក៏ដូចជាខេត្តព្រះសីហនុផងដែរ ដែលបានផ្តល់ឱ្យនូវមធ្យោបាយបំរើឱ្យវិស័យ ដឹកជញ្ជូន ពាណិជ្ជកម្ម និងទេសចរណ៍នៅក្នុងតំបន់ ដើម្បីសំរេចគោលដៅយុទ្ធសាស្ត្រនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា។ ជាងនេះទៅទៀត ជាមួយនឹងតំលៃវិនិយោគទុនសរុបចំនួន ៤៤០ លានដុល្លាអាមេរិល (ចរិកាវិនិយោគបរទេស) និងប្រាក់ចំណូលពន្ធប្រចាំឆ្នាំនៃការប្រតិបត្តិគំរោងនឹងជាកត្តាមួយដើម្បីគាំទ្រដល់ការរីកចំរើននៃសេដ្ឋកិច្ចជាតិ។

ដោយផ្អែកទៅលើការវិភាគហិរញ្ញវត្ថុនៃគំរោងស្នើសុំអភិវឌ្ឍន៍ ត្រូវបានរំពឹងថា នឹងបង្កើតអត្រាធនលាភភាពប្រមាណជា ៤០ភាគរយ។ គំរោងនេះ ត្រូវបានរំពឹងថានឹងទទួលបានផលជាវិជ្ជមានល្អប្រសើរ។

គេអាចសន្និដ្ឋានថា គំរោង**មរកត**នឹងមានផលប៉ះពាល់តិចទៅមធ្យមលើសង្គម និងធនធានធម្មជាតិ ប៉ុន្តែវាបានផ្តល់ឱ្យនូវប្រយោជន៍ជាវិជ្ជមានយ៉ាងច្រើនដល់សេដ្ឋកិច្ចមូលដ្ឋាន និងសេដ្ឋកិច្ចជាតិ ព្រោះគំរោងនេះមិនគ្រាន់តែបំរើឱ្យវិស័យទេសចរណ៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបំរើឱ្យវិស័យអភិវឌ្ឍន៍ផ្សេងៗទៀត ដូចជា ឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម ទូរគមនាគមន៍ និងវិស័យដទៃទៀត។ អាស្រ័យហេតុនេះ ប្រាក់ចំណូលជាច្រើន និងផលប្រយោជន៍



Draft

ដែលបានមកពីវិស័យអភិវឌ្ឍន៍ខាងលើនឹងបង្កើនកំរិតជីវភាពរបស់ប្រជាជន និងការរីកចំរើនសេដ្ឋកិច្ចនៃខេត្តព្រះសីហនុ ព្រមទាំងសេដ្ឋកិច្ចជាតិ។ ម្យ៉ាងវិញទៀត គំរោងនេះបានឆ្លើយតបផ្ទាល់ទៅនឹង “ **យុទ្ធសាស្ត្រចតុកោណ” ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី២** ក្នុងចតុកោណទី២ មុំទី១ និងក្នុងចតុកោណទី៣ មុំទី១ និងមុំទី២។

## *៩.២ អនុសាសន៍*

ចេញពីការវាយតំលៃលើសកម្មភាពគំរោងទាំងមូល នឹងមានហេតុប៉ះពាល់មួយចំនួនទៅលើធនធានបរិស្ថាន និងធនធានសង្គមនៅក្នុងតំបន់គំរោង ដូចនេះអនុសាសន៍សំខាន់ៗមួយចំនួនខាងក្រោមនឹងត្រូវអនុវត្តដើម្បីធានាដល់ការការពារធនធានបរិស្ថានក្នុងការអភិវឌ្ឍឱ្យមាននិរន្តរភាព :-

១. ក្រុមហ៊ុនកោះពស់នឹងអនុវត្តតាមរាល់បទដ្ឋានសុវត្ថិភាពការងារ និងច្បាប់ការងារ។ ឧបករណ៍ និងសំភារះមួយចំនួននឹងត្រូវបានផ្តល់ឱ្យដើម្បីការពារគ្រោះថ្នាក់ផ្សេងៗដល់កម្មករ និងបុគ្គលិកគំរោង។

២. ក្រុមហ៊ុនកោះពស់នឹងគោរពតាមរាល់បទបញ្ជា និងច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា ដែលជាប់ទាក់ទងទៅនឹងសកម្មភាពអភិវឌ្ឍន៍គំរោង។

៣. ត្រួតពិនិត្យជាប្រចាំនូវសំណល់រាវចេញពីអាងធ្វើប្រព្រឹត្តកម្មសំអាតនៃសមាសភាពអភិវឌ្ឍន៍នៅលើកោះពស់ និងលើឆ្នេរបារាំង ឱ្យស្របតាមស្តង់ដាបង្ហូរចេញនៃសំណល់រាវដែលបានកំណត់ដោយក្រសួងបរិស្ថាន។

៤. គ្រប់គ្រងកាកសំណល់គ្រប់ប្រភេទដែលកើតចេញពីគំរោងឱ្យបានល្អត្រឹមត្រូវ។

៥. សហប្រតិបត្តិការល្អជាមួយភ្នាក់ងារ ឬស្ថាប័នដែលពាក់ព័ន្ធ រាជធានីមូលដ្ឋាន រាជធានីខេត្ត ព្រមទាំងស្ថាប័នរាជរដ្ឋាភិបាលក្នុងកំរិតថ្នាក់ជាតិអំឡុងពេលសាងសង់ និងប្រតិបត្តិគំរោងទាំងមូល។

៦. ម្ចាស់គំរោង និងអ្នកម៉ៅការសាងសង់ត្រូវតែអនុវត្តឱ្យបានហ្មត់ចត់តាមវិធានការបន្ធូរបន្ថយ និងកម្មវិធីត្រួតពិនិត្យ ដូចដែលបានរៀបចំដាក់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាននៃរបាយការណ៍ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងរបាយការណ៍ការពារបរិស្ថានផ្សេងៗទៀតនៅក្នុងកិច្ចសន្យាសាងសង់ និងឯកសារដទៃទៀតសំរាប់គំរោងវិនិយោគទាំងមូល។

Draft

**ក្រុមហ៊ុនកោះពស់ (ខេមបូឌា)អ៊ិនវេសមេនគ្រុប** ពេញចិត្តចូលរួមក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍទីក្រុងនៅក្នុងខេត្តព្រះសីហនុនៃប្រទេសកម្ពុជា ហើយនឹងគោរពតាមច្បាប់វិនិយោគទាំងអស់ និងច្បាប់ការពារបរិស្ថាននៃរាជរដ្ឋាភិបាលកម្ពុជា។ ទន្ទឹមនេះដែរ **ក្រុមហ៊ុន**សំណូមពរទៅក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធដទៃទៀត ព្រមទាំងរាជរដ្ឋាភិបាលកម្ពុជាផ្តល់ការគាំទ្រ និងផ្តល់លិខិតអនុញ្ញាតលើការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានសំរាប់គំរោងនេះ ដោយផ្អែកទៅលើច្បាប់វិនិយោគ និងច្បាប់ស្តីអំពីកិច្ចការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ។

| | |
|---|---|
| រាជធានីភ្នំពេញ, ថ្ងៃទី..........ខែ...............ឆ្នាំ ២០១១ | រាជធានីភ្នំពេញ, ថ្ងៃទី..........ខែ...............ឆ្នាំ ២០១១ |
| KPIG-**ក្រុមហ៊ុនវិនិយោគ** | KCC- **ក្រុមហ៊ុនរៀបចំរបាយការណ៍** IESIA |
| **នាយកគំរោង** | **អគ្គនាយក** |
| **លោក ANDREW HALTURIN** | **លោក សោម មិថុនារត្ន័** |

Draft

## ឯកសារយោង


១- គោលការណ៏ណែនាំស្តីពីការវាយតំលៃបរិស្ថានរបស់ធនាគារអភិវឌ្ឍន៏អាស៊ី ADB. ខែសីហា ឆ្នាំ ២០០៣

២- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា . ឆ្នាំ ១៩៩៣

៣- គោលការណ៏ណែនាំទូទៅក្នុងការធ្វើរបាយការណ៏វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញរបស់ក្រសួងបរិស្ថាន ខែកញ្ញា ឆ្នាំ២០០៩

៤- "**យុទ្ធសាស្ត្រចតុកោណ**" ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី២. ខែកញ្ញា ឆ្នាំ ២០០៨

៥- ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងតំបន់ធម្មជាតិ .ខែធ្នូ ១៩៩៦

៦- ច្បាប់ការងារ នៃព្រះរាជាណាចក្រកម្ពុជា ខែមិនា ឆ្នាំ១៩៩៧

៧- ច្បាប់ភូមិបាល របស់ព្រះរាជាណាចក្រកម្ពុជា, ខែសីហា ឆ្នាំ ២០០១ ។

៨- ច្បាប់ស្តីអំពីជលផល, ខែឧសភា ឆ្នាំ២០០៦

៩- ច្បាប់ព្រៃឈើ ខែ សីហា ឆ្នាំ ២០០២

១០- ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា, ខែ ឧសភា ឆ្នាំ២០០៧ ។

១១- អនុក្រឹត្យលេខ ៧២ អ.ន.ក្រ.បក ស្តីពីកិច្ចដំណើការវាយតំលៃផលប៉ះពាល់បរិស្ថាន ខែសីហា ឆ្នាំ១៩៩៩

១២- អនុក្រឹត្យលេខ ២៧ អ.ន. ក.បក ស្តីពីការគ្រប់គ្រងការបំពុលទឹក ខែ មេសា ឆ្នាំ១៩៩៩

១៣- អនុក្រឹត្យលេខ ៣៦ អ.ន.ក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹង ខែ មេសា ឆ្នាំ១៩៩៩

១៤- អនុក្រឹត្យលេខ ៤២ អ.ន.ក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង ខែកក្កដា ឆ្នាំ ២០០០

១៥- កម្មវិធីសាងសង់ទូទៅនៃការងារសាងសង់ស្ពានកោះពស់ ខែមិនា ឆ្នាំ ២០០៨

១៦- កិច្ចសន្យាជួលកោះពស់ ក្រុងព្រះសីហនុ ខែកញ្ញា ឆ្នាំ២០០៦

១៧- កិច្ចសន្យាជួលឆ្នេរកោះពស់ ( ឆ្នេរហាវ៉ៃ) ក្រុងព្រះសីហនុ ខែកញ្ញា ឆ្នាំ២០០៦


Draft

១៨- កិច្ចសន្យាបន្ថែមស្តីពី ការកែសំរួលខ្លឹមសារក្នុងកិច្ចសន្យាជួលកោះពស់ និងដីឆ្នេរកោះពស់ (ឆ្នេរហាវ៉ៃ) ក្រុងព្រះសីហនុ ពាក់ព័ន្ធនឹងការប្តូរទីតាំងសាងសង់គល់ស្ពាន (ផ្នែកដីគោក)តភ្ជាប់ពីផ្នែកដីគោក ទៅកោះ ខែតុលា ឆ្នាំ២០០៧

១៩- ប្លង់មេ និងគ្រោងពេលនៃការអភិវឌ្ឍន៍កោះពស់ និងឆ្នេរហាវ៉ៃ ក្រុងព្រះសីហនុ ខែតុលា ឆ្នាំ២០០៧

២០- ការចូលរួមគ្រប់គ្រងនៃធនធានតំបន់ឆ្នេរ នៅកម្ពុជា ដំណាក់កាលទី៣ ខែមិថុនា ដល់វិច្ឆិកា ឆ្នាំ២០០៥

២១- របាយការណ៍បញ្ចប់នៃការសិក្សាអង្កេតផ្កាថ្មនៅជុំវិញកោះពស់ ក្រុងព្រះសីហនុ ខែធ្នូ ២០០៩

២២- របាយការណ៍បញ្ចប់នៃការសិក្សាជលផល នៅតំបន់កោះពស់ ក្រុងព្រះសីហនុ ខែធ្នូ ២០០៩

២៣- ការសិក្សា និងធ្វើសារពើភ័ណ្ឌព្រៃឈើ និងសត្វព្រៃនៅលើកោះពស់ ក្រុងព្រះសីហនុ ខែកញ្ញា ២០០៩

២៤- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ក្រុងព្រះសីហនុ ឆ្នាំ២០០៦-២០១០ ខែមិនា ឆ្នាំ២០០៦

២៥- របាយការណ៍ស្តីពី ផែនការយុទ្ធសាស្ត្រ របស់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះសីហនុ ឆ្នាំ ២០០៨

២៦- ផែនការសកម្មភាពអភិវឌ្ឍន៍ ខេត្តព្រះសីហនុ ឆ្នាំ ២០០៩-២០១៣

Draft